# មេរៀនទី ៤០: អ័ប្រាហាំស្តាប់បង្គាប់ព្រះ

## លោកុប្បត្តិ ២២:១-១៨

**គោលបំណង៖** យើងជាកុមារត្រូវទុកចិត្ត និងស្តាប់បង្គាប់ព្រះ

**ខគម្ពីរចងចាំ៖ ចោទិយកថា ៦:១៨** *"ក៏ត្រូវតែប្រព្រឹត្តការទៀងត្រង់ ហើយល្អនៅព្រះនេត្ររបស់ ព្រះយេហូវ៉ា ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
អ័ប្រាហាំអាចស្តាប់បង្គាប់ព្រះបានពីព្រោះគាត់ទុកចិត្តទ្រង់។ តើព្រះបានឱ្យអ្នកឲ្យថ្វាយអ្វីទៅចំពោះទ្រង់? សូមអរព្រះគុណព្រះដែលបានជួយឲ្យអ្នកទុកចិត្តនិងស្តាប់បង្គាប់ទ្រង់។ ពេលដែលយើងបន្តស្តាប់បង្គាប់ព្រះដូចជាអ័ប្រាហាំបានធ្វើ សេចក្តីជំនឿយើងនឹងរីកចំរើន ហើយទំនាក់ទំនងយើងជាមួយព្រះរាជបុត្រាព្រះយេស៊ូវគ្រីស្ទក៏រីកចំរើនដែរ។

**ចំរៀង៖** ១. លោកតាអ័ប្រាហាំ ២.ខ្ញុំទុកចិត្តលើព្រះយេស៊ូវ ៣. កូនតូចៗអើយ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត**

**ល្បែងកំសាន្តទី១ «ស្តេចបញ្ជា - សំរាប់កូនក្មេង ឬកុមារវ័យជំទង់)»**
**របៀបលេង៖**

- យើងលេងល្បែងស្តេចបញ្ជាដោយគ្រូដើរតួធ្វើជាស្តេច នៅពេលដែលកុមារឮពាក្យ "ស្តេចបញ្ជា"
- កុមារត្រូវធ្វើតាមអ្វីដែលគ្រូបានប្រាប់ដូចជា ប៉ះក្បាល លោតឡើង ឬ សើច...។
- បើមិនឮពាក្យ "ស្តេចបញ្ជា" កុមារមិនត្រូវធ្វើតាមនោះទេ។
- ពេលខ្លះគ្រូអាចធ្វើបន្លំឲ្យកុមារធ្វើខុសតាមដែរ ដោយគ្រូធ្វើកាយវិការតែមិននិយាយពាក្យថា "ស្តេចបញ្ជា" ទេ។



**ល្បែងកំសាន្តទី២ (សំរាប់ក្មេងជំទង់)**

- បិទភ្នែកកុមារម្នាក់ (អាចយកក្រមា ឬ ក្រណាត់មករុំភ្នែករបស់គាត់)។
- ហើយយកស្ករគ្រាប់ទៅបិទលើជញ្ជាំងដែលនៅឆ្ងាយពីកុមារម្នាក់នោះដោយមិនប្រាប់គាត់ថាជារបស់អ្វីឡើយ (អាចយកស្កុតមកប្រើ)។
- ឲ្យកុមារម្នាក់ទៀត(មិនបិទភ្នែក) ប្រាប់កុមារដែលបិទភ្នែកនោះពីទិសដៅទៅរកស្ករគ្រាប់នោះ
- គ្រូត្រូវប្រាប់កុមារដែលត្រូវគេបិទភ្នែកនោះថា គាត់ត្រូវទុកចិត្តលើការបង្ហាញណែនាំពីដៃគូរបស់ពួកគេ ហើយឲ្យគាត់ស្តាប់តាម ទោះជាគាត់គិតថាមិនសូវជាសមហេតុសមផលក៏ដោយ។
- កុមារមានពេល១នាទី ដើម្បីស្វែងរកស្ករគ្រាប់ឲ្យឃើញ។

សូមចងចាំថា វាមានសារៈសំខាន់ប៉ុណ្ណាចំពោះកុមារដែលត្រូវបានគេបិទភ្នែក និងត្រូវស្ដាប់តាមដៃគូរបស់គេ។ នេះគឺដូចគ្នានឹងការដែលយើងស្ដាប់បង្គាប់ព្រះដែរ ព្រះមានហេតុផលគ្រប់យ៉ាងសម្រាប់អ្វីៗដែលទ្រង់ចង់ឱ្យយើងថ្វាយទៅទ្រង់ បើទោះបីជាយើងគិតថាមិនសមហេតុផលក៏ដោយ តែយើងអាចទុកចិត្តទ្រង់បាន។ យើងអាចដឹងថានៅពេលដែលយើងស្ដាប់បង្គាប់ព្រះ រឿងល្អៗនឹងកើតមានឡើងទោះជាយើងអាចនឹងមើលមានអារម្មណ៍ថាមិនសមទំនងក៏ដោយ។

## ៤. ការណែនាំមេរៀន

ថ្ងៃនេះយើងនឹងរៀនពីលោកអ័ប្រាហាំ ដែលបានធ្វើឲ្យព្រះមានព្រះទ័យរីករាយដោយការស្ដាប់បង្គាប់របស់គាត់។ ការស្ដាប់បង្គាប់គឺមានន័យថា យើងទុកចិត្តលើអ្វីដែលព្រះអង្គបានប្រាប់ឱ្យយើងធ្វើ ហើយយើងធ្វើដោយក្ដីអំណរចេញពីចិត្ត។ ពេលខ្លះយើងមិនចូលចិត្តធ្វើអ្វីដែលអ្នកដទៃប្រាប់យើងឲ្យធ្វើទេ។ តើមានកូនៗប៉ុន្មាននាក់នៅទីនេះដែលតែងតែស្ដាប់បង្គាប់ឪពុកម្ដាយគ្រប់យ៉ាង? ហើយមានកូនៗប៉ុន្មាននាក់ដែលមិនស្ដាប់តាមឪពុកម្ដាយ? ថ្ងៃនេះយើងនឹងសិក្សាពីលោកអ័ប្រាហាំថាការស្ដាប់បង្គាប់ព្រះដោយរបៀបណាដែលធ្វើឲ្យព្រះសព្វព្រះទ័យ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

អ័ប្រាហាំគឺជាគំរូដ៏ល្អម្នាក់នៃអ្នកដែលទុកចិត្ត និង ស្ដាប់បង្គាប់ព្រះ។ ព្រះបានសន្យាជាមួយអ័ប្រាហាំថាគាត់នឹងមានកូនចៅជាច្រើន គឺច្រើនជាងផ្កាយនៅលើមេឃ ប៉ុន្តែអ័ប្រាហាំមានកូនប្រុសដំបូងរបស់គាត់ឈ្មោះអ៊ីសាកនៅពេលដែលគាត់ចាស់ណាស់ទៅហើយ គឺនៅពេលដែលគាត់មានអាយុ១០០ឆ្នាំ។ តើព្រះអាចបំពេញនូវការសន្យារបស់ទ្រង់បានទេ បើទោះបីជាអ័ប្រាហាំមានវ័យចំណាស់ទើបតែមានកូនប្រុសតែម្នាក់ដូច្នេះនោះ?

មុនពេលដែលព្រះអាចប្រទានកូនចៅច្រើនដូចជាផ្កាយនៅលើមេឃដល់អ័ប្រាហាំ គាត់ត្រូវស្ដាប់បង្គាប់ទ្រង់ជាមុនសិន។ ព្រះអង្គមានបន្ទូលទៅអ័ប្រាហាំឲ្យថ្វាយអ៊ីសាកជាយញ្ញបូជាទៅចំពោះទ្រង់នៅពេលដែលអ៊ីសាកនៅតូចនៅឡើយ។ នេះគឺមានន័យថាគាត់ត្រូវសម្លាប់កូនរបស់គាត់។ យើងពិបាកយល់ពីហេតុផលរបស់ព្រះថាហេតុអ្វីបានជាទ្រង់បង្គាប់ឲ្យអ័ប្រាហាំធ្វើបែបនេះ ប៉ុន្តែអ័ប្រាហាំនៅតែទុកចិត្តព្រះហើយធ្វើតាមការបង្គាប់របស់ទ្រង់។

អ័ប្រាហាំបាននាំអ៊ីសាកឡើងទៅលើភ្នំម៉ូរីយ៉ាជាកន្លែងដែលព្រះបានបង្គាប់គាត់ឲ្យទៅ។ គាត់បានត្រៀមខ្លួនដើម្បីបូជាអ៊ីសាកកូនប្រុសរបស់គាត់។ ខណៈពេលដែលអ័ប្រាហាំរៀបចំបូជាយញ្ញនោះ ព្រះបានឃាត់អ័ប្រាំហាំហើយប្រាប់គាត់មិនឲ្យធ្វើបាបក្មេងនោះឡើយ។ ព្រះជ្រាបដឹងយ៉ាងច្បាស់ថា អ័ប្រាហាំស្រលាញ់ព្រះជាជាងអ្វីគ្រប់យ៉ាងហើយមិនថាមានរឿងអ្វីក៏ដោយក៏អ័ប្រាហាំនៅតែស្ដាប់បង្គាប់ព្រះជានិច្ច។ អ៊ីសាកក៏បានធំពេញវ័យហើយបង្កើតបានកូនចៅជាច្រើនរហូតធ្វើឱ្យអ័ប្រាហាំមានកូនចៅជាច្រើនដូចជាផ្កាយនៅលើមេឃពិតមែន។

ត្រូវចាំថា ព្រះទ្រង់មិនចង់យករបស់ជាទីស្រលាញ់របស់ប្អូនៗចេញពីប្អូនៗទេ តែព្រះអង្គចង់ឲ្យប្អូនៗស្រឡាញ់ទ្រង់ជាទី ១ នៅក្នុងចិត្តដូចអ្វីដែលអ័ប្រាហាំបានធ្វើ។

## ៦. សំនួរពិភាក្សា

១. តើអ្នកគិតថាហេតុអ្វីបានជាអ័ប្រាហាំស្តាប់តាមការបង្គាប់របស់ព្រះដោយយកអ៊ីសាកធ្វើជាយញ្ញបូជា? *អ័ប្រាហាំទុកចិត្តព្រះ អ័ប្រាហាំដឹងថាព្រះជ្រាបដឹងថាអ្វីដែលល្អវិសេសសំរាប់គាត់*

២. តើយើងបានរៀនអ្វីខ្លះពីអ័ប្រាហាំក្នុងការស្តាប់បង្គាប់ព្រះ? *យើងត្រូវតែស្តាប់បង្គាប់ព្រះ មិនថាការបង្គាប់បញ្ជារនោះចំលែកយ៉ាងណាក៏ដោយ យើងនៅតែអាចទុកចិត្តព្រះនៅពេលដែលយើង ស្តាប់បង្គាប់ទ្រង់*

## ៧. ខគម្ពីរចងចាំ លោទិយកថា ៦:១៨

សូមជួយសិស្សចងចាំខគម្ពីរនេះ ៖

- ចែកខគម្ពីរខាងលើជា៤ផ្នែកហើយសរសេរនៅលើផ្ទាំងក្រដាសផ្សេងៗគ្នា
- ចែកកុមារជា៣ឬ៤ក្រុម ហើយឲ្យក្រុមនីមួយៗឈរនៅជ្រុងម្ខាងៗនៃថ្នាក់រៀន
- នៅពេលគ្រូស្រែកឲ្យក្រុមនីមួយៗ ត្រូវតែប្តូរកន្លែងគ្នាឈរ
- ឲ្យក្រុមដែលប្តូរកន្លែងរួចអានខគម្ពីរដែលនៅលើផ្ទាំងនោះ(ចាប់តាំងពីផ្ទាំងទី១ដល់ទី៤ឲ្យ ឮៗ)
- គ្រូអាចនាំកុមារលេងហ្គេមនេះរហូតដល់កុមារចងចាំខគម្ពីរនេះបាន។

## ៨. ហាត្ថកម្ម

**ហត្ថកម្មទី១៖** យើងអាចកាត់មួកពីក្រដាសកាតុងឬក្រដាសផ្សេងដែលវែង ហើយអាចបត់ធ្វើជារង្វង់មូលដែលអាចពាក់លើក្បាលបាន ហើយឲ្យកុមារផាត់ពណ៌វាឲ្យស្អាត។ ដើម្បីឆ្លើយតបទៅនឹងមេរៀននៅថ្ងៃនេះ សូមឱ្យកុមារសរសេរឈ្មោះរបស់ពួកគេនៅផ្នែកកណ្តាលមួករបស់ពួកគេ។ វាជាការរំលឹកឲ្យគេស្តាប់បង្គាប់ ឬការប្តេជ្ញាចិត្តនឹងធ្វើឲ្យបាន។ ចុងក្រោយយើងកិបក្រដាសវែងនោះឲ្យប៉ុននិងទំហំក្បាលកុមារ។






ឧទាហរណ៍៖ ការប្តេជ្ញាចិត្តនឹងធ្វើឲ្យបាន កុមារសរសេរ: “សុខឿនស្តាប់បង្គាប់ព្រះអង្គ ” ។

**ហត្ថកម្មះទី២.**កុមារអាចផាត់ពណ៌រូបភាពដែលមាននៅលើទំព័រខាងក្រោមនេះ។

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*


បិតទីនេះ:

# អ័ប្រាហាំស្តាប់បង្គាប់ព្រះ



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________

______________________________